**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ

ថ្ងៃសុក្រទី០៨ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង៩:០០នាទីនៅក្នុងរោងចក្រណាហ្គាភីសខបភើរេសិនលីមីតធីត(បោកគក់)។ អាស័យដ្ឋាន ផ្លូវជាតិលេខ០១ ភូមិព្រែកត្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ប្រទេសកម្ពុជា។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងក្រុមហ៊ុន និងប្រធានក្រុម ព្រមទាំងតំណាងកម្មករនិយោជិតទាំងអស់។

## ១. សមាសភាពអ្នកចូលរួម

### ក. ភាគីតំណាងអោយក្រុមហ៊ុន

-លោក Xu Zongwu (ប្រធានរោងចក្រ)

-លោក លី គាត (ប្រធានផ្នែករដ្ឋបាល)

### ខ. ភាគីតំណាងសហជីពនិងតំណាងកម្មករនិយោជិត

១-លោក សោម គីមសាន ២-លោក សំ សាមី ៣-លោក សឿន ស៊ីនួន ៤-លោកភ្លឹង ហួន

៥-លោក ពិន ផល្លីន ៦-លោក គង់ វណ្ណដេត ៧-លោក វណ្ណ រិទ្ធី ៨-លោក ឃឿន សុខា

៩-លោកស្រី យ៉ុន សម្បត្តិ ១០-លោកស្រី ខឿន សុខហេង ១១-លោកស្រី ពុំ រតនា

១២-លោក រឹម គង់ ១៣-លោក យ៉ុង សុខមឿន ១៤-ព្រមទាំងប្រធានក្រុមគ្រប់ផ្នែកគ្រប់ក្រុម។

## ២.ខ្លឹមសារអង្គប្រជុំ

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរការងារនៅក្នុងរោងចក្រក្នុងរយៈពេល ០៣ថ្ងៃដោយចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ ដោយពុំសូវមានការបញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្មុគ្រចិត្តដោះស្រាយដោយផ្ដល់ឲ្យភាគីនីមួយៗមានលទ្ធភាពទទួលយកបាន និងបង្កលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្ដែងដោយទាំងតំណាងរោងចក្រ ក៏ដូចជាផ្នែកតំណាងកម្មករនិយោជិតបានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាងក្រោម៖

១.រោងចក្របានឯកភាពផ្ដល់ជូនប្រាក់ឈ្នួលកម្មករនិយោជិតចំនួន៣០ដុល្លាក្នុង១ខែកំឡុងពេលព្យួរការងារ។

Scanned with CamScanner

២.តំណាងរោងចក្រ ឯកភាពតាមសំណើររបស់តំណាងកម្មករ សហជីពមូលដ្ឋាន និងប្រធានក្រុមទាំងអស់ហើយនៅពេលក្រោយភាគីកម្មករនិយោជិតឯកភាពត្រូវធ្វើតាមនិតិវិធីនៃការចរចានិងគោរពតាមនិតិវិធីច្បាប់។

## ៣.លទ្ធផលអង្គប្រជុំ

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១-រោងចក្រចាប់ផ្តើមព្យួរការងារ កម្មករនិយោជិត ចំនួន៤១៧នាក់។ ចាប់ផ្តើមពីថ្ងៃទី១៣ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ ។

២. រោងចក្រផ្តល់ប្រាក់ឈ្នួលគោល៣០ដុល្លាក្នុង១ខែក្នុងពេលព្យួរការងារ ។

៣.ករណីដែលរោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួររោងចក្រអនុញ្ញាតិអោយកម្មករនិយោជិតចូលធ្វើការមុនពេលកំណត់។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១១:00 នាទីនាថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

## ក.ភាគីតំណាងសហជីព និងតំណាងកម្មករនិយោជិត

១-លោក សោម គឹមសាន    ២-លោក សំ សាមី    ៣-លោក សឿន ស៊ីនួន    ៤-លោកភ្លឹង ហួន

៥-លោក ពិន ផល្លីន    ៦-លោក គង់ វណ្ណដេត    ៧-លោក វណ្ណ រិទ្ធី    ៨-លោក យឿន សុខា

៩-លោកស្រី យ៉ុន សម្បត្តិ    ១០-លោកស្រី ខឿន សុខហេង    ១១-លោកស្រី ពុំ រតនា

Scanned with CamScanner

១២-លោក រីម គង់

១៣-លោក យ៉ុង សុខមឿន

ហត្ថលេខា និងត្រា

**ប្រធានរោងចក្រ**

Scanned with CamScanner